DEVELOPMENTAL DISABILITIES ADMINISTRATION (DDA)

# ព័ត៌មានអំពី ICAP សម្រាប់អ្នកឆ្លើយតប

# Information about the ICAP for Respondents

តើអ្វីទៅជា **ICAP** ?

បញ្ជីសារពើភ័ណ្ឌសម្រាប់ការធ្វើផែនការអ្នកជម្ងឺ និងទីភ្នាក់ងារ (ICAP) គឺជាឧបករណ៍វាយតម្លៃ ដែលជួយក្នុងការកំណត់ថាតើបុគ្គលម្នាក់ៗអាចមានសិទ្ធិទទួលបានការគ្រប់គ្រងការអភិវឌ្ឍពិការភាព (DDA) បានឬយ៉ាងណា ។ ICAP គឺត្រូវបានគ្រប់គ្រង ដើម្បីកំណត់ថាតើអ្នកដាក់ពាក្យមាន "ការកម្រិតអ្វីសំខាន់" ដូចដែលមានចែងក្នុងច្បាប់ (WAC 388-823) ឬយ៉ាងណា។

តើនរណាអាចគ្រប់គ្រង **ICAP** ?

នាយកដ្ឋានត្រូវផ្តល់ និងរៀបចំសម្រាប់ការគ្រប់គ្រងនៃ ICAP ។ នាយកដ្ឋាននេះកំណត់អ្នកណា ដែលគួរប្រើប្រាស់ជា "អ្នកឆ្លើយ" (WAC 388-823-0930) ។

តើនរណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្លាយជាអ្នកឆ្លើយ?

ឪពុកម្តាយ គ្រូបង្រៀន ឬបុគ្គលថែទាំទាំងឡាយ ដែលស្គាល់ជាមួយបុគ្គលដែលកំពុងត្រូវបានវាយតម្លៃច្បាស់អាចផ្តល់ព័ត៌មាន ដែលត្រូវការដើម្បីបំពេញ ICAP ។ ICAP គឺត្រូវបានបំពេញដោយអ្នកឆ្លើយតបម្នាក់ ដែលបានស្គាល់អ្នកជម្ងឺយ៉ាងហោចណាស់រយៈបីខែ និងដែលពិនិត្យគាត់ ឬនាងលើមូលដ្ឋានជារៀងរាល់ថ្ងៃ។ ប្រសិនបើមិនមាននរណាម្នាក់បំពេញបានតាមនិយមន័យរបស់អ្នកឆ្លើយតប ICAP មិនអាចត្រូវបានគ្រប់គ្រងឡើយ។ ដោយមិនមានអ្នកឆ្លើយតបដ៏មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ DDA មិនអាចកំណត់ភាពអាចមានសិទ្ធិទទួលស្ថិតក្រោមលក្ខខណ្ឌណាមួយ ដែលតម្រូវឱ្យមាន ICAP (WAC 388-823-0940) ។

តើនាយកដ្ឋអាចត្រូវការអ្នកឆ្លើយតបប៉ុន្មាននាក់?

នាយកដ្ឋានអាចត្រូវការអ្នកឆ្លើយតបកាន់តែឆាប់តាមតែចាំបាច់ ដើម្បីទទួលព័ត៌មានពេញលេញ និងត្រឹមត្រូវអំពីលទ្ធភាពរបស់អ្នកដាក់ពាក្យ។

តើអ្នកដាក់ពាក្យអាចជាអ្នកឆ្លើយតបដែរទេ?

ទេ។ អ្នកដាក់ពាក្យអាចផ្តល់នូវទិន្នន័យបញ្ចូល ប៉ុន្តែនឹងមិនអាចជាអ្នកឆ្លើយតបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ។

តើអ្នកដាក់ពាក្យអាចត្រូវបានគេស្នើឱ្យឆ្លើយសំណួរនានា ឬបង្ហាញនូវកិច្ចការមួយចំនួនឬទេ?

DDA អាចប្រឹក្សា អង្កេត ឬស្នើឱ្យអ្នកដាក់ពាក្យបង្ហាញនូវកិច្ចការមួយចំនួន ដើម្បីផ្ទៀងផ្ទាត់ចម្លើយនានា។ "យោងតាមការប៉ាន់ស្មានរបស់អ្នកលើព័ត៌មាន ឬការអង្កេតនៃការបំពេញមុខងារលើកិច្ចការស្រដៀងគ្នា ឬទាក់ទងគ្នា។" (សៀវភៅណែនាំអ្នកប្រើប្រាស់ ICAP ឧបសម្ព័ន្ធ D ទំព័រទី153)

"ដើម្បីឱ្យលទ្ធផលនានាមានសុពលភាព វាចាំបាច់ថាព័ត៌មានដែលបានថតទុកឆ្លុះបញ្ចាំងពីអាកប្បកិរិយាពិតរបស់អ្នកជម្ងឺក្នុងស្ថានភាពធម្មតា។។" ព័ត៌មានអាចត្រូវបានទទួលពីកូនសៀវភៅ ICAP ពីបទសម្ភាសន៍ដោយប្រើប្រាស់កូនសៀវភៅនេះ ឬសូម្បីតែបានពីការស្នើសុំឱ្យអ្នកជម្ងឺសំដែងធាតុមួយ។ វាមិនមានបំណងថានេះត្រូវជាតេស្តសំដែងឡើយ ប៉ុន្តែ ប្រសិនបើចាំបាច់ វាអាចសមស្របក្នុងការប្រើប្រាស់ទិន្នន័យអនុវត្ត រួមជាមួយព័ត៌មានដែលបានផ្តល់ឱ្យដោយអ្នកឆ្លើយតបម្នាក់។" (ថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2003 អ៊ីម៉ែលពី Brad Hill ទៅកាន់ DDA)

តើអ្នកឆ្លើយតបនេះត្រូវបានតម្រូវឱ្យធ្វើអ្វីខ្លះ?

អ្នកឆ្លើយតបត្រូវបានតម្រូវឱ្យឆ្លើយសេចក្តីថ្លែងការណ៍នីមួយៗស្តីពី ICAP ជាមួយ មួយក្នុងចម្លើយបួនចម្លើយ ដែលកំណត់សមត្ថភាពបុគ្គលម្នាក់ៗបានល្អបំផុត។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃចម្លើយទាំងនេះ៖

| | |
|---|---|
| <u>មិនដែល ឬ កម្រ (0)</u> | បង្ហាញថាកិច្ចការនេះគឺពិបាកពេក ឬ បុគ្គលនេះមិនត្រូវបានអនុញ្ញាតឱ្យធ្វើកិច្ចការនេះឡើយ ពីព្រោះវាមិនមានសុវត្ថិភាព។ បុគ្គលនេះមិនដែល ឬ កម្របំពេញផ្នែកទាំងអស់នៃកិច្ចការនេះ ដោយគ្មានជំនួយ សូម្បីតែត្រូវបានស្នើសុំក៏ដោយ។ |
| <u>ធ្វើ ប៉ុន្តែមិនបានល្អ (1)</u> | ពេលខ្លះបុគ្គលម្នាក់បំពេញកិច្ចការនេះ ដោយគ្មានជំនួយ ប៉ុន្តែធ្វើមិនបានល្អនោះទេ។ ទោះបីជាគាត់/នាងបានព្យាយាមធ្វើផ្នែកទាំងអស់នៃកិច្ចការនេះ ដោយគ្មានជំនួយ ឬការត្រួតត្រា លទ្ធផលគឺមិនបានល្អឡើយ។ វាមិនអីទេ ប្រសិនបើគាត់/នាងត្រូវការការស្នើសុំ ឬរលឹក។ បុគ្គលនេះធ្វើការប្រមាណជា 25 ភាគរយនៃពេលនេះ។ |

<u>ធ្វើបានល្អមធ្យម (2)</u> បុគ្គលម្នាក់បំពេញកិច្ចការដោយសមហេតុផលបានល្អ ដោយគ្មានជំនួយ ឬការត្រួតត្រា។ ទោះបីជាបុគ្គលម្នាក់នេះមិនបានបំពេញកិច្ចការនេះបានពេញលេញក៏ដោយ គាត់/នាងអាចធ្វើវាបានគ្រប់ផ្នែកទាំងអស់។ វាមិនអីទេ ប្រសិនបើគាត/នាងត្រូវការការស្នើសុំ ឬរលឹក។ បុគ្គលនេះធ្វើការប្រមាណជា 75 ភាគរយនៃពេលនេះ។

<u>ធ្វើបានល្អខ្លាំងណាស់ (3)</u> បង្ហាញពីឯករាជ្យពេញលេញលើធាតុមួយ។ បុគ្គលនេះបានបំពេញនូវជំនាញនេះ ឬជំនាញនេះគឺងាយស្រួលពេកសម្រាប់គាត់/នាង។ បុគ្គលនេះធ្វើកិច្ចការបានពេញលេញ ហើយបានល្អខ្លាំងណាស់ ដោយគ្មានជំនួយ ឬការត្រួតត្រាពីនរណាម្នាក់ ហើយដឹងពីពេលចាំបាច់ដែលត្រូវធ្វើកិច្ចការនានា ដោយមិនត្រូវបានស្នើសុំ ឬរំលឹកឡើយ។ គាត់/នាងធ្វើកិច្ចការនេះបានល្អណាស់--ជានិច្ច ឬ សឹងតែជានិច្ច។

តើផ្នែកអក្បកិរិយាប្រែប្រួលតាម **ICAP** វាយតម្លៃបញ្ហាអក្បកិរិយាមែនទេ?

ទេ។ DDA មិនវាយតម្លៃអាកប្បកិរិយានានា នៅពេលកំណត់ភាពអាចទទួលបានសិទ្ធឡើយ។ គោលបំណងរបស់ ICAP គឺដើម្បីវាយតម្លៃជំនាញដែលអាចប្រែប្រួលក្នុងតំបន់នានានៃជំនាញម៉ូទ័រ ជំនាញរស់នៅផ្ទាល់ខ្លួន ជំនាញសង្គម និងទំនាក់ទំនង និងជំនាញរស់នៅក្នុងសហគមន៍។

"ការផ្តោតនៃរបស់ផ្នែកអក្បកិរិយាប្រែប្រួលតាម ICAP គឺស្ថិតលើសមត្ថភាព។ នរណាម្នាក់ ដែល ប្រសិនបើអស់កម្លាំង ខឹង ឬឆាប់ខឹង ពេលខ្លះបដិសេធបំពេញកិច្ចការ អាចនៅតែបានវាយតម្លៃ 'ធ្វើបានល្អដោយមិនត្រូវបានស្នើសុំ' ប្រសិនបើជំនាញនេះគឺនៅក្នុងសមត្ថភាពរបស់បុគ្គល ហើយវាជាធម្មតាត្រូវបានបំពេញបានល្អ។ ប្រសិនបើការបដិសេធគឺនៅតែមាន ប៉ុន្តែអនុវត្តតែលើកិច្ចការប្រែប្រួលជាក់លាក់ពីរបីប៉ុណ្ណោះ ភាគច្រើនវាអាចកាត់បន្ថយការវាយតម្លៃនៃការប្រែប្រួលរបស់អ្នកជម្ងឺតាមចំនុចមួយលើធាតុជាក់លាក់ទាំងនេះ។"

អក្បកិរិយានានាដែលរំខានជាមួយសកម្មភាពប្រចាំថ្ងៃរបស់អ្នកជម្ងឺម្នាក់ ឬជាមួយសកម្មភាពនានារបស់អ្នកដែលនៅជុំវិញគាត់/នាង គួរតែត្រូវបានវាយតម្លៃជាបញ្ហាអក្បកិរិយា <u>មិនមែនជាកង្វះខាតអក្បកិរិយាប្រែប្រួលតាមនោះទេ</u>។ ការបដិសេធក្នុងការបំពេញកិច្ចការចាំបាច់នានា ដែលស្ថិតនៅក្នុងសមត្ថភាពរបស់បុគ្គលម្នាក់ ពេលខ្លះត្រូវបានហៅថាអក្បកិរិយាមិនប្រព្រឹត្តតាម ឬមិនសហការ អាចត្រូវបានកត់ត្រាក្នុងផ្នែកអក្បកិរិយាមានបញ្ហានៃ ICAP ប្រសិនបេិការបដិសេធនេះគឺគ្រប់គ្រាន់ជាទូទៅក្នុងការបង្កើតបញ្ហាជាបន្តឆ្លងកាត់ជំនាញដែលប្រែប្រួលតាមនានា។ ក្នុងករណីនេះ ភាពមិនសហការរបស់អ្នកជម្ងឺនឹងមិនធ្វើឱ្យចុះខ្សោយពីពិន្ទុធាតុអក្បកិរិយាដែលប្រែប្រួលតាមរបស់គាត់/នាងដែលគួរតែត្រូវបានវាយតម្លៃលើមូលដ្ឋានសមត្ថភាពជាជាងការសហការ។"

[ពីលើបណ្តាញរបស់ Brad Hill "សេចក្តីណែនាំសម្រាប់បំពេញមាត្រដ្ឋានអក្បកិរិយាដែលប្រែប្រួលតាម ICAP/SIB-R"

(http://www.cpinternet.com/~bhill/icap/)]

តើអ្នកដាក់ពាក្យត្រូវបានតម្រូវឱ្យមានវត្តមានកំឡុងពេល **ICAP** ដែរឬទេ?

អ្នកដាក់ពាក្យត្រូវតែមានវត្តមាន ហើយអាចរកបានយ៉ាងហោចណាស់ផ្នែកនៃការសម្ភាសន៍។ អ្នកដាក់ពាក្យ និងអ្នកឆ្លើយតបអាចជ្រើសរើសឆ្លើយតបជាឯកជន ឬ ក្នុងវត្តមានរបស់អ្នកចូលរួមផ្សេងទៀត។ វាសំខាន់ ដែលអ្នកឆ្លើយតបផ្តល់នូវព័ត៌មានត្រឹមត្រូវ ដូច្នេះអ្នកឆ្លើយតបត្រូវតែប្រាប់នាយកដ្ឋាននេះ ប្រសិនបើមានអ្វីមួយកំពុងរំខានជាមួយភាពពិតប្រាកដ និងស្មោះត្រង់របស់ពួកគេ។

តើ **ICAP** ត្រូវបានដាក់ពិន្ទុយ៉ាងដូចម្តេច?

ការឆ្លើយតបរបស់ ICAP ត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រ។ កម្មវិធីកុំព្យូគណនាពិន្ទុបទដ្ឋានសម្រាប់ផ្នែកជំនាញដែលប្រែប្រួលតាមទាំងបួន ដោយយកអាយុរបស់អ្នកដាក់ពាក្យចូលទៅក្នុងគណនី។

តើ **ICAP** ប៉ះទង្គិចដល់ការសម្រេចចិត្តលើភាពអាចទទួលបានសិទ្ធិយ៉ាងដូចម្តេច?

នៅពេល ICAP ត្រូវបានតម្រូវជាភស្តុតាងនៃការកម្រិតសំខាន់។ដើម្បីអាចមានសិទ្ធិទទួលបាន DDA ពិន្ទុលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវតែនៅ ឬនៅក្រោយពិន្ទុវិស័យឯករាជ្យទូលំទូលាយជាក់លាក់ចំពោះអាយុរបស់អ្នកជម្ងឺ/អ្នកដាក់ពាក្យ (WAC 388-823-0900) ។

DEVELOPMENTAL DISABILITIES ADMINISTRATION (DDA)

ព័ត៌មានអំពី **ICAP** សម្រាប់អ្នកឆ្លើយតប

# សេចក្តីប្រកាសពីការយល់ដឹង

## Declaration of Understanding

| |
|---|
| តប៖ អ្នកដាក់ពាក្យ ________________________________________ |

ខ្ញុំបានអាន និងយល់ “ព័ត៌មានអំពី ICAP សម្រាប់អ្នកឆ្លើយតប។”

ខ្ញុំបានទទួល “សេចក្តីណែនាំសម្រាប់បំពេញមាត្រដ្ឋានអក្សកិរិយាដែលប្រែប្រួលតាម ICAP/SIB-R”
https://www.dshs.wa.gov/sites/default/files/FSA/forms/pdf/16-182.pdf

ខ្ញុំយល់ដឹងថា ចម្លើយនានាដែលខ្ញុំផ្តល់ ត្រូវតែមានភាពត្រឹមត្រូវ ហើយនឹងត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃការកម្រិតសំខាន់សម្រាប់ភាពអាចទទួលសិទ្ធិរបស់ DDA ។

ខ្ញុំយល់ដឹងថា បុគ្គលម្នាក់ដែលត្រូវបានវាយតម្លៃប្រហែលជាអាច ឬមិនអាចបំពេញបាននូវលក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលសិទ្ធិរបស់ DDA ។

ខ្ញុំបានមានរាល់ឱកាសនីមួយៗក្នុងការសួរសំណួរ ហើយចម្លើយទាំងអស់របស់ខ្ញុំត្រូវបានផ្តល់ចម្លើយតាមការពេញចិត្តរបស់ខ្ញុំ។

| | |
|---|---|
| ហត្ថលេខាអ្នកឆ្លើយតប | កាលបរិច្ឆេទ |
| អ្នកតំណាង DSHS / DDA | កាលបរិច្ឆេទ |

សម្គាល់៖ ការបដិសេធមិនចុះហត្ថលេខាលើសេចក្តីប្រកាសនេះនឹងលើកលែងបុគ្គលនេះពីការពិចារណាជា “អ្នកឆ្លើយតប” ។

ការចែកចាយ៖

ច្បាប់ចម្លងចំពោះអ្នកឆ្លើយតប

ច្បាប់ចម្លងចំពោះឯកសារដែលទទួលបាន